**The School District of Philadelphia**
Office of Student Rights & Responsibilities
440 N. Broad Street, Second Floor
Philadelphia, PA 19130
Office: 215.400.4830 ~ Fax: 215.400.4226

Rachel Holzman, Esquire
អនុប្រធាន

# សេចក្តីជូនដំណឹងអំពីការការពារនៃការកែប្រែច្បាប់ស្តីអំពីសិទ្ធិរបស់សិស្ស (PPRA)

PPRA ផ្តល់សិទ្ធិដល់មាតាបិតារបស់សិស្សសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នូវសិទ្ធិមួយចំនួនដែលទាក់ទងនឹងការស្ទង់មតិ ការប្រមូល និងការប្រើព័ត៌មានសម្រាប់គោលបំណងនៃទីផ្សារ និងការពិនិត្យរាងកាយ។ សិទ្ធិទាំងនេះរួមមាន ប៉ុន្តែមិនកំណត់ចំពោះ សិទ្ធិក្នុងការៈ

- ព្រមព្រៀងមុនពេលសិស្សត្រូវបានតម្រូវឱ្យផ្តល់ការស្ទង់មតិដែលទាក់ទងនឹងការការពារមួយ ឬលើសពីនេះ ដូចមានខាងក្រោមនេះ («ការស្ទង់មតិដែលមានការការពារព័ត៌មាន») ប្រសិនបើការស្ទង់មតិនេះត្រូវបានផ្តល់ប្រាក់ជំនួយទាំងអស់ ឬមួយចំនួន ដោយកម្មវិធីរបស់ក្រសួងអប់រំសហរដ្ឋអាមេរិក (U.S. Department of Education) -
    1. ការចូលរួមក្នុងគណបក្សនយោបាយ ឬជំនឿរបស់សិស្ស ឬមាតាបិតារបស់សិស្ស។
    2. បញ្ហាខួរក្បាល ឬផ្លូវចិត្ត របស់សិស្ស ឬគ្រួសាររបស់សិស្ស។
    3. អាកប្បកិរិយា ឬចរយា អំពីការរួមភេទ។
    4. អាកប្បកិរិយាដែល ខុសច្បាប់ មិនចូលសង្គម ទាក់ទិននឹងបទក្រិដ្ឋ ឬការប្រមាថ។
    5. វាយតម្លៃមិនល្អចំពោះអ្នកដទៃ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រួសាររបស់អ្នកផ្តល់ចម្លើយ។
    6. មានទំនាក់ទំនងជាសម្ងាត់ដែលស្របតាមច្បាប់ ដូចជា ជាមួយមេធាវី វេជ្ជបណ្ឌិត ឬបុព្វជិត។
    7. មានទំនាក់ទំនង ឬកាន់សាសនា ឬជំនឿ របស់សិស្ស ឬមាតាបិតារបស់សិស្ស។ ឬ
    8. ប្រាក់ចំណូល ដែលមិនមែនតម្រូវឡើងដោយច្បាប់ ដើម្បីសម្រេចសិទ្ធិដែលអាចចូលរួមក្នុងកម្មវិធី។

- ទទួលលិខិតជូនដំណឹង និងឱកាសជ្រើសរើសសិស្សចេញពី -
    1. ការស្ទង់មតិដែលមានការការពារព័ត៌មានអ្វីមួយផ្សេងទៀត ដោយមិនគិតពីប្រាក់ជំនួយ។

2. រាល់ការពិនិត្យ ឬការពិនិត្យរាងកាយដែលមិននៅក្នុងភាពអាសន្ន ដែលតម្រូវតាមលក្ខណៈ វត្តមានអវត្តមាន ផ្តល់ឲ្យដោយសាលា ឬភ្នាក់ងាររបស់សាលា ហើយមិនចាំបាច់ដើម្បីការពារសុខភាព និងសុវត្ថិភាពភ្លាមៗរបស់សិស្ស លើកលែងតែ ការស្តាប់ ចក្ខុវិស័យ ឬជម្ងឺកោងឆ្អឹងខ្នង ឬការពិនិត្យ ឬការត្រួតពិនិត្យរាងកាយ ដែលត្រូវបានអនុញ្ញាត ឬតម្រូវឲ្យដោយច្បាប់រដ្ឋ។ ហើយ
3. សកម្មភាពដែលពាក់ព័ន្ធនឹង ការប្រមូល ការបញ្ចេញ ឬការប្រើព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលពីសិស្ស សម្រាប់ទីផ្សារ ឬការលក់ ឬចែកចាយព័ត៌មានទៅអ្នកដទៃ។ (នេះមិនពាក់ព័ន្ធនឹង ការប្រមូល ការបញ្ចេញ ឬការប្រើព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលពីសិស្ស សម្រាប់គោលបំណងនៃការអភិវឌ្ឍន៍ ការវាយតម្លៃ ឬការផ្តល់ផលិតផល ឬសេវាកម្ម សម្រាប់ ឬទៅសិស្ស ឬស្ថាប័នអប់រំនោះទេ។)

- ត្រួតពិនិត្យ តាមការស្នើសុំ និងមុនពេលចាត់ការ ឬប្រើ –
    1. ការពារព័ត៌មាននៃការស្ទង់មតិរបស់សិស្ស និងការស្ទង់មតិដែលបង្កើតដោយភាគីទីបី។
    2. ឧបករណ៍ដែលប្រើដើម្បីប្រមូលព័ត៌មានផ្ទាល់ខ្លួនពីសិស្សសម្រាប់ទីផ្សារ ការលក់ ឬគោលបំណងចែកចាយអ្វីមួយផ្សេងទៀតខាងលើនេះ។ និង
    3. សម្ភារៈបង្ហាត់បង្រៀនដែលប្រើជាផ្នែកនៃកម្មវិធីសិក្សា។

សិទ្ធិទាំងនេះផ្ទេរពីមាតាបិតាទៅសិស្សដែលមានអាយុ ១៨ ឆ្នាំ ឬជាក្មេងដែលមានសេរីភាព ក្រោមច្បាប់របស់រដ្ឋ។

ក្រសួងអប់រំបានបង្កើតច្បាប់ ដោយមានការពិគ្រោះយោបល់ជាមួយមាតាបិតា ដែលទាក់ទងនឹងសិទ្ធិទាំងនេះ ព្រមទាំងរៀបចំដើម្បីការពារភាពឯកជនរបស់សិស្សក្នុងការគ្រប់គ្រងព័ត៌មាននៃការស្ទង់មតិដែលមានការការពារ និង ការប្រមូល ការបញ្ចេញ ឬការប្រើព័ត៌មានផ្ទាល់ខ្លួនសម្រាប់ទីផ្សារ ការលក់ ឬគោលបំណងនៃការចែកចាយផ្សេងទៀត។ គោលការណ៍របស់ក្រុមប្រឹក្សាក្រសួងអប់រំលេខ 235.1 (ការស្ទង់មតិសិស្ស) ពិពណ៌នាអំពីសិទ្ធិរបស់ឪពុកម្តាយ/អាណាព្យាបាល និងសិស្ស ទាក់ទងនឹងការស្ទង់មតិសិស្ស។ នៅពេលការស្ទង់មតិមានសំណើសម្រាប់ព័ត៌មានដែលត្រូវបានការពារ មាតាបិតា/អាណាព្យាបាល មានសិទ្ធិទទួលព័ត៌មានអំពីការស្ទង់មតិទាំងនេះដែលផ្តល់ទៅសិស្ស និងមានសិទ្ធិក្នុងការត្រួតពិនិត្យ តាមការស្នើសុំការស្ទង់មតិបែបនេះ មុននឹងចាត់ការ ឬចែកចាយដល់សិស្ស។ មាតាបិតា/អាណាព្យាបាល ក៏មានសិទ្ធិដកកូនរបស់គាត់ចេញពីការស្ទង់មតិដែលស្នើសុំព័ត៌មានដែលមានការការពារផងដែរ។

ក្រសួងអប់រំក៏នឹងជូនដំណឹងដោយផ្ទាល់ផងដែរ ដូចជាតាមរយៈ ប៉ុស្តសំបុត្រអាមេរិក ឬអ៊ីមែល មាតាបិតារបស់ សិស្សដែលបានគ្រោងពេលចូលរួមក្នុងសកម្មភាពអ្វីមួយ ឬការស្ទង់មតិដែលបានកត់សម្គាល់ខាងក្រោមនេះ ហើយ នឹងផ្តល់ឱកាសឱ្យមាតាបិតាដកយកកូនរបស់គាត់ចេញពីការចូលរួមក្នុងសកម្មភាពអ្វីមួយ ឬការស្ទង់មតិ។ មាតាបិតាក៏នឹងត្រូវ

បានផ្តល់ឱកាសឱ្យពិនិត្យឡើងវិញនូវការស្ទង់មតិដែលពាក់ព័ន្ធផងដែរ។ សម្រាប់ការស្ទង់មតិ និងសកម្មភាពដែលបានគ្រោងទុកបន្ទាប់ពីឆ្នាំសិក្សាចាប់ផ្តើម មាតាបិតានឹងត្រូវបានផ្តល់ការជូនដំណឹងដែលសមហេតុផលអំពីសកម្មភាពដែលបានគ្រោងទុក និងការស្ទង់មតិដែលមានរាយខាងក្រោមនេះ ហើយ ត្រូវបានផ្តល់ឱកាសឱ្យជ្រើសរើសដកកូនរបស់គាត់ចេញពីសកម្មភាព និងការស្ទង់មតិទាំងនេះ។ មាតាបិតាក៏នឹងត្រូវបានផ្តល់ឱកាសឱ្យពិនិត្យឡើងវិញនូវការស្ទង់មតិដែលពាក់ព័ន្ធផងដែរ។ ខាងក្រោមនេះជាបញ្ជីនៃសកម្មភាពអ្វីមួយ និងការស្ទង់មតិដែលមាននៅក្នុងតម្រូវការនៃការជូនដំណឹងផ្ទាល់នេះ៖

- ការប្រមូល ការបញ្ចេញ ឬការប្រើព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលពីសិស្សសម្រាប់ ទីផ្សារ ការលក់ ឬការចែកចាយផ្សេងទៀត។
- ការចាត់ចែងព័ត៌មាននៃការស្ទង់មតិដែលបានការពារណាមួយ ដែលមិនផ្តល់ប្រាក់ជំនួយទាំងអស់ ឬមួយចំនួនដោយក្រសួងអប់រំ។
- រាល់ការពិនិត្យដែលមិននៅក្នុងភាពអាសន្ន ការពិនិត្យរាងកាយដែលជ្រៀតជ្រែក ឬការពិនិត្យពិច័យដូចបានរៀបរាប់ខាងលើនេះ។

មាតាបិតាដែលជឿថាសិទ្ធិរបស់គាត់ត្រូវបានគេបំពាន អាចដាក់ពាក្យបណ្តឹងជាមួយ៖

Student Privacy Policy Office
U.S. Department of Education
400 Maryland Avenue, SW
Washington, DC 20202